ពិនិត្យOK?

# ប្រាក់បៀវត្សអប្បបរមា



*ទាំងអ្នកធ្វើការងារ*
*ទាំងអ្នកជួលបុគ្គលិកឲ្យធ្វើការងារ*
*កុំភ្លេច*

ប្រាក់បៀវត្សអប្បបរមា គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមា នៃប្រាក់បៀវត្សសម្រាប់បុគ្គលិកគ្រប់គ្នា។

## ខេត្តណាហ្គាណុ យូ ប្រាក់បៀវត្សអប្បបរមា

ចាប់ពីថ្ងៃទី 2 ខែតុលា ឆ្នាំ2026 នេះតទៅ
ចំនួនទឹកប្រាក់ក្នុងមួយម៉ោង

**1,117 យ៉េន**

ធៀបនឹងឆ្នាំមុន UP 56 យ៉េន

**ទាំងអ្នកដែលប្រាក់ខែតាមខែ ទាំងអ្នកដែលប្រាក់ខែតាមថ្ងៃ តស់សាកគណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោងមើល**

カンボジア語版

ក្រសួងសុខាភិបាល
ការងារនិងសុខុមាលភាព

របៀបគណនា សូមមើលផ្នែកខាងក្រោយ!

# តស់គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោងហើយប្រៀបធៀបនឹងប្រាក់បៀវត្សអប្បបរមា!



"ប្រព័ន្ធប្រាក់បៀវត្សអប្បបរមា" ត្រូវអនុវត្តចំពោះអ្នកធ្វើការងារទាំងអស់
ទោះបីមានអាយុ ឬរបៀបធ្វើការខុសគ្នាដូចជា ការងារមិនពេញម៉ោង
ឬសិស្សនិស្សិតជាដើមក៏ដោយ។ សូមបំពេញប្រាក់បៀវត្សដែលចង់ឆែក(*1)
និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តនៃកន្លែងធ្វើការ
ចូលតារាងប្រៀបធៀប រួចប្រៀបធៀបវា!(*2)

## វិធីប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា

សូមសរសេរចូលនូវចំនួនទឹកប្រាក់បៀវត្សរបស់អ្នក
និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តដែលត្រូវនឹងអ្នក។(*2)

**A អ្នកដែលមានប្រាក់ខែតាមម៉ោង**

ប្រាក់ខែតាមម៉ោង ____ យ៉េន ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ____ យ៉េន

**B អ្នកដែលមានប្រាក់ខែតាមថ្ងៃ**

ប្រាក់ខែតាមថ្ងៃ ____ យ៉េន ÷ ចំនួនមធ្យមនៃម៉ោងធ្វើការក្នុងមួយថ្ងៃដែលកំណត់ ____ ម៉ោង = ចំនួនទឹកប្រាក់ក្នុងមួយម៉ោង ____ យ៉េន ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ____ យ៉េន

**C អ្នកដែលមានប្រាក់ខែតាមខែ**

ប្រាក់ខែតាមខែ ____ យ៉េន ÷ ចំនួនជាមធ្យមនៃម៉ោងធ្វើការក្នុងមួយខែដែលកំណត់ ____ ម៉ោង = ចំនួនទឹកប្រាក់ក្នុងមួយម៉ោង ____ យ៉េន ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ____ យ៉េន

**D អ្នកដែលរួមបញ្ចូលគ្នាចំណុច A B និង C ខាងលើ**

ឧទាហរណ៍ ក្នុងករណីដែលប្រាក់ខែគោល គឺប្រាក់ខែតាមថ្ងៃ ប៉ុន្តែប្រាក់បន្ថែមផ្សេងៗ (ដូចជាប្រាក់បន្ថែមនៅលើភារកិច្ច) ត្រូវបានបើកជូនជាប្រចាំខែ

① ប្រាក់ខែគោល (ប្រាក់ខែតាមថ្ងៃ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា B
② ប្រាក់បន្ថែមផ្សេងៗ (ប្រាក់ខែតាមខែ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា C
③ ចំនួនទឹកប្រាក់សរុបដែលបូក ① និង ② ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)

(*1) ក្នុងការប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា មិនគិតរួមនូវប្រាក់បៀវត្សដូចតទៅ៖
① ប្រាក់បៀវត្សដែលទូទាត់បណ្តោះអាសន្ន (ដូចជាប្រាក់ឧបត្ថម្ភសម្រាប់ការរៀបអាពាហ៍ពិពាហ៍) ② ប្រាក់បៀវត្សដែលទូទាត់រាល់រយៈពេលដែលលើស១ខែ (ដូចជាប្រាក់រង្វាន់លើកទឹកចិត្ត) ③ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការដែលហួសពីម៉ោងការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមទៅលើការងារថែមម៉ោង) ④ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការក្នុងថ្ងៃដែលមិនមែនជាថ្ងៃការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារនៅថ្ងៃឈប់សម្រាក) ⑤ ចំនួនលើសពីចំនួនទឹកប្រាក់ដែលគណនាប្រាក់បៀវត្សតាមម៉ោងការងារធម្មតា ក្នុងប្រាក់បៀវត្សដែលទូទាត់ចំពោះការងារក្នុងរយៈពេលចាប់ពីម៉ោង១០យប់ រហូតដល់ម៉ោង៥ព្រឹក (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារពេលយប់) ⑥ ប្រាក់បន្ថែមសម្រាប់ការវត្តមានមិនឈប់សោះ ប្រាក់បន្ថែមសម្រាប់ការធ្វើដំណើរ និងប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារ
(*2) វិធីគណនាលម្អិត និងវិធីគណនាក្នុងករណីប្រាក់ខែតាមលទ្ធភាពស្នាដៃ សូមទាក់ទងមកមន្ទីរការងារឬការិយាល័យត្រួតពិនិត្យស្តង់ដារការងារនៅជិតលោកអ្នកបំផុត

## 業務改善助成金

ជួយឧបត្ថម្ភយ៉ាងច្រើនបំផុត ត្រឹម 600 ម៉ឺនយ៉េន

## លោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម

## តោះនាំគ្នាប្រើ "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" ដែលគាំទ្រការដំឡើងប្រាក់បៀវត្ស!

### អ្វីទៅជា "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" ?

"ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" គឺជាប្រាក់ឧបត្ថម្ភដែលផ្តល់ជំនួយដល់សហគ្រាសតូចនិងមធ្យម និងប្រតិបត្តិករអាជីវកម្មខ្នាតតូចដែលមានគោលដៅវិនិយោគលើបរិក្ខារដែលរួមចំណែកដល់ការបង្កើនផលិតភាព ហើយទន្ទឹមគ្នានេះដំឡើង "ប្រាក់បៀវត្សទាបបំផុតនៅក្នុងកន្លែងធ្វើអាជីវកម្ម (ប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម)"។ ក្នុងករណីដែលបានធ្វើការវិនិយោគលើបរិក្ខារជាដើម យើងនឹងឧបត្ថម្ភមួយផ្នែកនៃចំណាយនោះអាស្រ័យតាមលក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យ។

**មជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរសព្ទ អំពីប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច**

0120-366-440

**ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន)**

業務改善助成金 検 索

**លក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យ ចម្បងៗ**

- ☑ ប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម គឺទាបជាងប្រាក់បៀវត្សអប្បបរមាតាមតំបន់សម្រាប់ឆ្នាំសារពើពន្ធ2026
- ☑ ដំឡើងប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម
- ☑ ទូទាត់ប្រាក់បៀវត្សក្រោយដំឡើង
- ☑ ដាក់បញ្ចូលម៉ាស៊ីនឧបករណ៍ និងសម្ភារៈជាដើមដើម្បីបង្កើនផលិតភាព
- ☑ គ្មានមូលហេតុនៃការមិនផ្តល់ការឧបត្ថម្ភ ដូចជាការបញ្ឈប់ពីការងារ ការបញ្ចុះប្រាក់បៀវត្សជាដើម

**ឧបត្ថម្ភមួយផ្នែកនៃចំណាយចាំបាច់សម្រាប់ការវិនិយោគលើសម្ភារៈជាដើម**

**ដំណាក់កាលរហូតដល់ការផ្តល់ប្រាក់ឧបត្ថម្ភ**

1. ដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភ និងផែនការអនុវត្តគម្រោងជាដើម ទៅមន្ទីរការងារនៃរាជធានីខេត្តដែលកន្លែងធ្វើអាជីវកម្មស្ថិតនៅ
   → ត្រួតពិនិត្យ
2. ក្រោយសម្រេចផ្តល់ប្រាក់ឧបត្ថម្ភ អនុវត្តគម្រោងតាមផែនការដែលបានដាក់ពាក្យមក
3. ដាក់របាយការណ៍លទ្ធផលនៃការអនុវត្ត និងពាក្យស្នើសុំផ្តល់ប្រាក់ឧបត្ថម្ភ ទៅមន្ទីរការងារ
   → ត្រួតពិនិត្យ
4. ផ្តល់ឲ្យ

**ឆែកតាម WEB!**

| | | |
|---|---|---|
| វេបសាយពិសេសដែលទាក់ទងនឹងប្រាក់បៀវត្សអប្បបរមា (មានតែភាសាជប៉ុន) 最低賃金　特設サイト 検 索 | ពាក់ព័ន្ធនឹងប្រាក់បៀវត្សអប្បបរមា សូមទាក់ទងមកមន្ទីរការងារខេត្តណាហ្គាណូ ឬការិយាល័យត្រួតពិនិត្យស្តង់ដារការងារនៅជិតលោកអ្នកបំផុត។ 長野労働局 検 索 | វេបសាយពិសេសអំពីការដំឡើងប្រាក់ឈ្នួល (មានតែភាសាជប៉ុន) មានផ្សព្វផ្សាយអំពីគោលនយោបាយគាំទ្រសម្រាប់ការដំឡើងប្រាក់ឈ្នួល។ 賃金引上げ特設ページ 検 索 |

**ផ្តល់ការប្រឹក្សាដោយឥតគិតថ្លៃជាមួយអ្នកជំនាញ**

អ្នកដែលមានកង្វល់អំពីការដំឡើងប្រាក់បៀវត្ស
សូមប្រឹក្សាជាមួយមជ្ឈមណ្ឌលគាំទ្រលើកកម្ពស់កំណែទម្រង់របៀបធ្វើការ។
ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援センター 検索

**មូលនិធិគាំទ្រកំណែទម្រង់របៀបធ្វើការ**

សាជីវកម្មហិរញ្ញវត្ថុនយោបាយជប៉ុន កំពុងផ្តល់ហិរញ្ញប្បទានសម្រាប់បរិក្ខារនិងប្រតិបត្តិការទៅកាន់និយោជកដែលខិតខំប្រឹងប្រែងដំឡើងប្រាក់បៀវត្សអប្បបរមានៅក្នុងកន្លែងធ្វើអាជីវកម្ម។
ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援資金 検索

リサイクル適性Ⓐ
この印刷物は、印刷用の紙へリサイクルできます。

(R8.9)